វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងកសិកម្ម

ប្រកាស/២៧៤៦ ប្រក.កសក/០២ សីហា ១៩៨៩/

ស្តីពីការប្រើប្រាស់ឯកសារពាក់ព័ន្ធ នឹងដីធ្លី

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ តាមក្រឹត្យលេខ០៣ ក្រ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យច្បាប់លេខ ០៧ ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃ ការធ្វើច្បាប់ និងបទបញ្ជា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធ ចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញសេចក្តីណែនាំអនុវត្តនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ០៣ សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម

សំរេច

មាត្រា១: ប្រកាសអោយប្រើជាផ្លូវការទូទាំងប្រទេសនូវ :

- ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី
- បង្កាន់ដៃទទួលពាក្យ ស្នើសុំកាន់កាប់
- សៀវភៅទទួលពាក្យ ស្នើសុំកាន់កាប់
- សៀវភៅចុះបញ្ជីអចលនវត្ថុ
- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី

ដែលក្រសួងកសិកម្មបានបោះពុម្ពលក់ចែកជូនតាមគំរូភ្ជាប់មកជាមួយនេះ។

មាត្រា២:

គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង ត្រូវចាត់តំណាងមកទាក់ទងនៅនាយកដ្ឋានសុរិយោដី ក្រសួងកសិកម្ម អំពីចំនួនសេចក្តីត្រូវការឯកសារខាងលើ ចាប់ពីថ្ងៃបានទទួលសេចក្តីប្រកាសនេះតទៅ។

មាត្រា៣:

មន្ទីរនាយកដ្ឋានសុរិយោដី នាយកដ្ឋានផែនការ-ស្ថិតិ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ មន្ទីរកសិកម្មខេត្ត-ក្រុង ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តប្រកាសនេះ។

មាត្រា៤:

ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ។

Downloaded from http://www.khmerlaws.com